**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១០២៨១ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ មានដូចតទៅ ៖

## I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ ៖

### ១- ការងារដាំដុះ ៖

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៩ ៥៨៦ហ.ត ស្មើនឹង ១០៤,៩៧%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៧ ៦២៨ហ.ត ស្មើនឹង ៥,១៧%។

### ២- ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់)៖

ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ១ ១៩១ ៥០២ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៩ ៥៨៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៣ ៥៤៦ ១១៩តោន លើសឆ្នាំមុន ១ ០៣៥ ៨៣២តោន។ ទិន្នផលគិតជាមធ្យម ២,៩៧៦តោន/ហ.ត (សប្តាហ៍មុន ៣,០៤៥តោន/ហ.ត) លើសឆ្នាំមុន ៩៤គ.ក្រ/ហ.ត។

## II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់)៖

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ១៧០ ៤០៩ហ.ត តិចជាងឆ្នាំមុនចំនួន ៩០ ៣១២ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៨ ៩០៤ហ.តស្មើនឹង ៥,២៣% និងដោយគ្រឿងយន្តចំនួន ១៦១ ៥០៥ហ.តស្មើនឹង ៩៤,៧៧%
- សាបបានសរុបចំនួន ២១៤ហ.ត តិចជាងឆ្នាំមុនចំនួន ៥៣១ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ១២៣ ៥៤៦ហ.ត ស្មើនឹង ២៨,៧៧%នៃផែនការ ៤២៩ ៣៥៥ហ.ត តិចជាងឆ្នាំមុន៨០ ៧៣៣ហ.ត។

**III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ១០ ២៦២ហ.ត ស្មើនឹង ១៤,០១% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុន ៤ ៥៤៣ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ១ ៦០៩ហ.ត ស្មើនឹង ១១,៣៩% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ២ ២៧២ហ.ត។

**IV. សេចក្តីសន្និដ្ឋាន**

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៩ ៥៨៦ហត ស្មើនឹង ១០៤,៩៧% នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៣៧ ៦២៨ហត។ មកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ៤៥,៨៣% នៃផ្ទៃដីអនុវត្ត ២ ៥៩៩ ៥៨៦ហត ដែលទទួលបានទិន្នផលគិតជាមធ្យម ២,៩៧៦តោន/ហ.ត និងកំពុងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំជាប្រចាំដល់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ត្រូវចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ម្យ៉ាងទៀតក្នុងកាលៈទេសៈដែលកសិករកំពុងតែប្រមូលផលស្រូវចុងរដូវវស្សានេះ ក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរហើយក្រសួងក៏បានណែនាំដល់អង្គភាពជំនាញពាក់ពន្ធ័ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ម៉ាស៊ីនកិនស្រូវនិងសហគមន៍កសិកម្មក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ ដែលអាចកើតឡើងជាយថាហេតុនៅពេលខាងមុខ។ ទន្ទឹមនឹងនេះ ក្រសួងបានរៀបចំកិច្ចប្រជុំក្រុមការងារផ្នែកស្រូវ អង្ករ (ក្រុម "ឈ") នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ នេះផងដែរ។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 143,771 | 2.833 | 407,251 | 58.20 | 28-11-2016 |
| 02 | បាត់ដំបង | 289,567 | 107,561 | 3.616 | 388,975 | 37.15 | 30-11-2016 |
| 03 | កំពង់ចាម | 89,861 | 37,874 | 3.470 | 131,432 | 42.15 | 24-11-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 26,637 | 2.765 | 73,643 | 21.41 | 28-11-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 9,536 | 2.809 | 26,789 | 8.28 | 23-11-2016 |
| 06 | កំពង់ធំ | 215,526 | 113,949 | 2.628 | 299,441 | 52.87 | 29-11-2016 |
| 07 | កំពត | 138,388 | 31,986 | 3.712 | 118,732 | 23.11 | 29-11-2016 |
| 08 | កណ្តាល | 35,329 | 9,443 | 3.787 | 35,761 | 26.73 | 29-11-2016 |
| 09 | កោះកុង | 10,503 | 4,921 | 2.751 | 13,538 | 46.85 | 29-11-2016 |
| 10 | ក្រចេះ | 33,072 | 21,839 | 2.040 | 44,561 | 66.03 | 29-11-2016 |
| 11 | មណ្ឌលគិរី | 23,608 | 12,965 | 2.685 | 34,807 | 54.92 | 29-11-2016 |
| 12 | ភ្នំពេញ | 10,291 | 1,180 | 2.900 | 3,422 | 11.47 | 29-11-2016 |
| 13 | ព្រះវិហារ | 82,398 | 62,503 | 2.933 | 183,347 | 75.85 | 28-11-2017 |
| 14 | ព្រៃវែង | 270,111 | 138,770 | 3.143 | 436,117 | 51.38 | 29-11-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 89,086 | 3.004 | 267,646 | 76.81 | 28-11-2016 |
| 16 | រតនគិរី | 26,185 | 20,955 | 2.220 | 46,520 | 80.03 | 30-11-2016 |
| 17 | សៀមរាប | 186,735 | 117,455 | 2.608 | 306,339 | 62.90 | 29-11-2016 |
| 18 | ព្រះសីហនុ | 16,605 | 3,652 | 2.212 | 8,080 | 21.99 | 28-11-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 25,749 | 2.500 | 64,372 | 89.79 | 29-11-2016 |
| 20 | ស្វាយរៀង | 168,528 | 46,417 | 2.880 | 133,681 | 27.54 | 29-11-2016 |
| 21 | តាកែវ | 197,444 | 70,360 | 3.772 | 265,416 | 35.64 | 29-11-2016 |
| 22 | ឧត្តរមានជ័យ | 86,501 | 57,343 | 2.511 | 143,988 | 66.29 | 28-11-2016 |
| 23 | កែប | 3,597 | 1,304 | 1.893 | 2,469 | 36.25 | 29-11-2016 |
| 24 | ប៉ៃលិន | 5,825 | 1,616 | 2.800 | 4,525 | 27.74 | 23-11-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 34,630 | 3.040 | 105,267 | 44.22 | 25-11-2016 |
| សរុប | | **2,599,586** | **1,191,502** | **2.976** | **3,546,119** | **45.83** | |
| តួលេខសប្តាហ៍មុន | | **2,597,412** | **917,865** | **3.045** | **2,794,835** | **35.34** | |
| តួលេខឆ្នាំ២០១៥ | | **2,561,958** | **870,903** | **2.882** | **2,510,287** | **33.99** | |
| ប្រៀបធៀបឆ្នាំមុន | | **37,628** | **320,599** | **0.094** | **1,035,832** | **11.84** | |

ភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

បានឃើញនិងឯកភាព

ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧
(គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដកស្ទូងរាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពព្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 9,934 | - | - | 9,934 | 100.00 | 1 | 30 | 9,468 | 9,498 | 53.15 | 28-11-2016 |
| 02 | បាត់ដំបង | 12,000 | - | | - | | - | | | | - | - | |
| 03 | កំពង់ចាម | 42,000 | 19,312 | 6,111 | 31.64 | 13,201 | 68.36 | 90 | 627 | 16,014 | 16,641 | 39.62 | 24-11-2015 |
| 04 | កំពង់ឆ្នាំង | 30,700 | 3,396 | - | - | 3,396 | 100.00 | - | - | 3,396 | 3,396 | 11.06 | 28-11-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 15,484 | - | - | 15,484 | 100.00 | 12 | 142 | 15,342 | 15,484 | 43.01 | 29-11-2016 |
| 07 | កំពត | 7,000 | 1,750 | - | - | 1,750 | 100 | | | 1,745 | 1,745 | 24.93 | 28-11-2017 |
| 08 | កណ្ដាល | 55,800 | 6,592 | 835 | 12.67 | 5,757 | 87.33 | - | - | 4,045 | 4,045 | 7.25 | 29-11-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,370 | 1,444 | 10.05 | 12,926 | 89.95 | 21 | 62 | 7,971 | 8,033 | 57.38 | 14-11-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | - | - | - | - | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 23,760 | - | - | 23,760 | 100.00 | - | - | 23,760 | 23,760 | 31.68 | 29-11-2016 |
| 15 | ពោធិសាត់ | 9,000 | 5,094 | - | - | 5,094 | 100.00 | - | - | 4,231 | 4,231 | 47.01 | 28-11-2016 |
| 16 | រតនៈគីរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 15,555 | - | - | 15,555 | 100.00 | 20 | 5 | 10,640 | 10,645 | 50.87 | 29-11-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 4,716 | - | - | 4,716 | 100.00 | - | - | 4,716 | 4,716 | 23.58 | 29-11-2016 |
| 21 | តាកែវ | 75,000 | 43,631 | 364 | 0.83 | 43,267 | 99.17 | - | - | 14,827 | 14,827 | 19.77 | 29-11-2016 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | - | | - | | - | | | | - | - | |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | | | | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 6,815 | 150 | 2.20 | 6,665 | 97.80 | 70 | 605 | 5,920 | 6,525 | 62.14 | 25-11-2016 |
| | សរុប | 429,355 | 170,409 | 8,904 | 5.23 | 161,505 | 94.77 | 214 | 1,471 | 122,075 | 123,546 | 28.77 | |
| | តួលេខសប្ដាហ៍មុន | 429,355 | 150,878 | 5,933 | 3.93 | 144,945 | 96.07 | 156 | 1,195 | 104,355 | 105,550 | 24.58 | |
| | តួលេខឆ្នាំមុន | 417,325 | 260,721 | 8,260 | 3.17 | 252,461 | 96.83 | 745 | 2,866 | 201,413 | 204,279 | 48.95 | |
| | ប្រៀបធៀបឆ្នាំមុន | 12,030 | -90,312 | 644 | 2.06 | -90,956 | -2.06 | -531 | -1,395 | -79,338 | -80,733 | | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ូខកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
ដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦)

| រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| ន្ទាយមានជ័យ | 225 | - | 8 | - | 6,250 | - | - | - | 1,325 | 344 | 120 | 1 | 7,920 | 353 | 4.46 |
| ាត់ដំបង | 460 | | | | | | 50 | | 960 | | 300 | | 1,770 | - | - |
| ពង់ចាម | 1,010 | 150 | 1,160 | 480 | 20 | - | 760 | 112 | 2,380 | 1,369 | 150 | 497 | 4,320 | 3,138 | 72.64 |
| ពង់ឆ្នាំង | 1,090 | 170 | | | 90 | | 230 | | 1,860 | | 1,800 | | 5,070 | - | - |
| ពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| ពង់ធំ | 130 | - | 46 | - | 90 | - | 60 | 45 | 345 | 86 | 20 | - | 645 | 177 | 27.44 |
| ពត | 200 | - | | | 135 | | 245 | | 590 | 30 | 255 | | 1,425 | 30 | 2.11 |
| ណ្តាល | 8,101 | 6,620 | | | 225 | | 190 | | 5,056 | | 4,307 | | 17,879 | - | - |
| កះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| ចេះ | 1,800 | 1,700 | 1,079 | 853 | - | - | 80 | - | 420 | 182 | 40 | 34 | 2,340 | 1,295 | 55.34 |
| ណ្ឌលគីរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| ពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| ះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| ព្រវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| ពធិ៍សាត់ | 200 | 100 | 43 | - | 850 | 63 | 350 | - | 500 | 66 | 300 | 5 | 2,200 | 177 | 8.05 |
| នគិរី | | | | | | | | | | | | | - | - | - |
| ៀមរាប | 830 | - | 77 | - | 2,490 | 85 | 265 | 50 | 2,040 | 342 | 1,850 | 50 | 7,475 | 604 | 8.08 |
| ះសីហនុ | 35 | | | | 140 | | 20 | | 175 | | | | 370 | - | - |
| ងត្រែង | 250 | - | 81 | | - | | - | 25 | 450 | 59 | 500 | | 1,200 | 165 | 13.75 |
| ាយរៀង | | | | | 7,100 | 81 | 110 | - | 1,170 | 215 | - | | 8,380 | 296 | 3.53 |
| កែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| ត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| ប | 150 | 30 | | | 30 | 14 | 100 | | 200 | | - | | 480 | 14 | 2.92 |
| លិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| ងឃ្មុំ | 5,210 | 8,942 | 1,070 | 914 | - | | 400 | 65 | 1,145 | 215 | 490 | 75 | 10,977 | 1,425 | 13,926 |
| **សរុប** | **18,713** | **12,595** | **2,901** | **1,333** | **19,521** | **1,941** | **2,585** | **629** | **11,350** | **4,009** | **12,067** | **782** | **73,249** | **10,262** | **14.01** |
| **ខសប្តាហ៍មុន** | **18,713** | **12,595** | **1,972** | **631** | **19,521** | **1,734** | **2,585** | **567** | **11,350** | **2,819** | **12,067** | **587** | **73,249** | **7,679** | **10.48** |
| **លេឆ្នាំមុន** | **10,504** | **188** | **5,488** | **3,879** | **4,174** | **2,317** | **4,116** | **572** | **11,804** | **4,256** | **12,100** | **2,172** | **42,698** | **14,805** | **34.67** |
| **បធៀបឆ្នាំមុន** | **8,209** | **12,407** | **-2,587** | **-2,546** | **15,347** | **(376)** | **-1,531** | **57** | **-454** | **-247** | **-33** | **-1,390** | **30,551** | **-4,543** | **-20.66** |

| រាជធានី-ខេត្ត | សណ្ដែកដី (ហ.ត) | | សណ្ដែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| ន្ទាយមានជ័យ | - | | - | | - | | 110 | 105 | - | | - | | 110 | 105 | 95.45 |
| ាត់ដំបង | 100 | | | | 100 | | 30 | | | | | | 230 | - | - |
| ំពង់ចាម | 790 | 107 | - | - | 30 | 548 | 360 | - | - | - | 3,380 | - | 4,560 | 655 | 14.36 |
| ំពង់ឆ្នាំង | 80 | | | | 760 | | 60 | | 10 | | 60 | | 970 | - | - |
| ំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| ំពង់ធំ | 199 | - | - | - | - | - | - | 27 | - | - | - | - | 199 | 27 | 13.57 |
| ំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| ណ្ដាល | 96 | | 50 | | 150 | | 442 | | - | | - | | 738 | - | - |
| កាះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| ្រចេះ | 120 | 54 | - | - | - | - | 110 | 89 | - | - | - | 48 | 230 | 191 | 83.04 |
| ណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| ្នំពេញ | - | | - | | | | | | | | | | - | - | - |
| ្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| ្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| ោធិ៍សាត់ | 550 | 4 | 50 | - | 200 | - | 720 | 25 | - | | - | | 1,520 | 29 | 1.91 |
| តនគិរី | | | | | | | | | | | | | - | - | - |
| សៀមរាប | - | - | 10 | - | 210 | - | 405 | 58 | - | - | - | - | 625 | 58 | 9.28 |
| ្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| ្ទឹងត្រែង | - | | - | | | | | | | | | | - | - | |
| ្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| ាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| កែប | 100 | 33 | - | - | - | - | 30 | 138 | - | | - | | 130 | 171 | 131.54 |
| ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| ត្បូងឃ្មុំ | 230 | 30 | - | - | - | 25 | 20 | 5 | - | - | 1,340 | - | 1,590 | 60 | 3.77 |
| សរុប | 3,624 | 299 | 110 | 5 | 2,616 | 590 | 3,785 | 667 | 10 | - | 4,780 | 48 | 14,121 | 1,609 | 11.39 |
| លេខសប្ដាហ៍មុន | 3,624 | 188 | 110 | 5 | 2,616 | 462 | 3,785 | 329 | 10 | - | 4,780 | - | 14,121 | 984 | 6.97 |
| តួលេខឆ្នាំមុន | 3,624 | 723 | 1,173 | 1,282 | 2,789 | 211 | 3,735 | 298 | 80 | - | 8,930 | 1,367 | 20,331 | 3,881 | 19.09 |
| ប្រៀបធៀបឆ្នាំមុន | - | -424 | -1,063 | -1,277 | -173 | 379 | 50 | 369 | -70 | - | -4,150 | -1,319 | -6,210 | -2,272 | -7.69 |

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៦

ជ. ប្រធានការិយាល័យស្ថិតិ